00285092 E2/94/2


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens


អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ
Case File/ Dossier N° 001/18-07-2007-ECCC/TC


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / MAR / 2009
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry


| | |
|---|---|
| ចំពោះមុខ | ចៅក្រម **និល ណុន** ប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ | ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៩ |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ |

## សេចក្តីសម្រេចអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះអ្នកដាក់ពាក្យសុំ E2/36 E2/51 និង E2/69

**សហព្រះរាជអាជ្ញា**

ជា លាង

Robert PETIT

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Piere Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-ECCC/TC តាម "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ ។

**ក្រោយពីបានទទួល** ពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់ដោយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/36 E2/51 និង E2/69 ("អ្នកដាក់ពាក្យសុំ")[1] ។

**បានឃើញ** ការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្ន ចំពោះអ្នកដាក់ពាក្យសុំ E2/36 និង E2/51 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩[2] ។

**ក្រោយពីបានពិចារណា** លើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ភាគីក្នុងអំឡុងពេលសវនាការបឋម ។

**រំលឹកឡើងវិញ** នូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់ភស្តុតាងលើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩[3] ។

**ក្រោយពីបានទទួល** ភស្តុតាងបញ្ជាក់បន្ថែមលើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/51 និង E2/69 ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩[4] ក្នុងទំរង់ជាប័ណ្ណបោះឆ្នោត និងលិខិតធានាអះអាងពីអត្តសញ្ញាណនៃអ្នកសុំចុះឈ្មោះបោះឆ្នោត ។

**កត់សម្គាល់ឃើញថា** មិនមានព័ត៌មានបន្ថែមណាមួយត្រូវបានដាក់រហូតមកទល់ពេលនេះទាក់ទងនិងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/36 គឺមានតែលិខិតបញ្ជាក់ទីលំនៅរបស់អ្នកដាក់ពាក្យសុំ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ ធ្វើឡើងដោយសមាគម អាដហុក ដែលសមាគមនេះមិនមែនជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការចេញលិខិតបញ្ជាក់ឡើយ[5] ។

---

[1] ដូចដែលបានចង្អុលបង្ហាញក្នុងអំឡុងពេលសវនាការបឋម អង្គជំនុំជម្រះសាលាដំបូង ជាវិធានការណ៍បណ្តោះអាសន្ន នឹងហៅរាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈលេខយោងឯកសារដែលមាននៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលបានដាក់បញ្ចូលក្នុងសំណុំរឿង ។

[2] សូមមើលឯកឯកសា E2/36 និង E2/51/5

[3] សូមមើលឯកឯកសា E2/94

[4] សូមមើលឯកឯកសា E2/94/1

[5] សូមមើលឯកឯកសា E2/36/4

## ហេតុដូច្នេះ

**យល់ឃើញថា** ឯកសារដែលបានដាក់ដោយអ្នកដាក់ពាក្យសុំ E2/51 និង E2/69 គឺមានភស្តុតាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ពីអត្តសញ្ញាណ ។

**យល់ឃើញថា** ឯកសារដែលអ្នកដាក់ពាក្យសុំ E2/36 បានដាក់ គឺមិនគ្រប់គ្រាន់ក្នុងការបញ្ជាក់អំពីអត្តសញ្ញាណ ។

**តម្កល់** នូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ E2/51 នៅក្នុងរឿងក្តីប្រឆាំងនិងជនជាប់ចោទខាងលើ ។

**សម្រេច** ទទួលស្គាល់អ្នកដាក់ពាក្យសុំ E2/69 ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីប្រឆាំងនិងជនជាប់ចោទខាងលើ ។

**សម្រេចបដិសេធ** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/36 នៅក្នុងរឿងក្តីប្រឆាំងនឹងជនជាប់ចោទខាងលើ ។

ភ្នំពេញ ថ្ងៃទី០៤ ខែ មីនា ឆ្នាំ ២០០៩

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

និល នន្ទ